**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា
# និងទិសដៅការងារខែឧសភា ឆ្នាំ២០១៧

**សេចក្តីផ្តើម** :

នៅក្នុងខែមេសានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:**

**១.មុខងារនីតិកម្ម:**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០២លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន ០១លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ និងសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ នៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយក្នុងចំណោមរដ្ឋាភិបាលនៃប្រទេសសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ<br>- ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល បម្រើភេសជ្ជៈ ផ្គត់ផ្គង់សម្ភារៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំចំនួន០៧លើក មានអ្នកចូលរួមចំនួន៤៤៨នាក់<br>- ថតចម្លងឯកសារបានចំនួន០៦សំណើ អស់ក្រដាសចំនួន២៧,៦៧៩សន្លឹក<br>- ទូទាត់ថ្លៃទិញសម្ភារៈ ថ្លៃអាហារសម្រន់ ឧបត្ថម្ភមន្ត្រីបំពេញការងារលើសម៉ោង និងថ្លៃឈប់សម្រាកចំនួន១១លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| គណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងក្រុមតំណាងរាស្ត្រហត្ថលេខី ដើម្បីពិនិត្យពិភាក្សាលើសេចក្តីស្នើច្បាប់ចំនួន០១ និងសេចក្តីព្រាងច្បាប់ចំនួន០១ ។ | ផ្សេងៗចំនួន៦៧នាក់ និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន៦៥នាក់<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់ពីរដ្ឋសភា និងរាជរដ្ឋាភិបាល និងបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន២៩ច្បាប់<br>- ធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា និងបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងធ្វើជំនួយស្មារតីសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន០៦ច្បាប់<br>- បានសិក្សាស្រាវជ្រាវ និងបកប្រែកិច្ចការសភានៃសាធារណរដ្ឋហ្វីលីពីន<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៥លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន១៨លើក<br>- ថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹងសេចក្តីប្រកាសព័ត៌មានចំនួន០៩លើក<br>- បានបញ្ចូលឯកសារច្បាប់របស់ព្រឹទ្ធសភា នីតិកាលទី១ និងទី២ ក្នុងគេហទំព័រ E-library ព្រឹទ្ធសភា ។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| វចនាសម្ព័ន្ធនយោបាយ | វចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបានៈ | - ធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និង |

| | |
|---|---|
| + អញ្ជើញជួបពិភាក្សាការងារ ជាមួយក្រុមប្រឹក្សាឃុំ ដើម្បីសិក្សាឈ្វេងយល់អំពីការអភិវឌ្ឍការងារកសាងផែនការអភិវឌ្ឍរបស់ឃុំ ការប្រែប្រួល បញ្ហាប្រឈម និងសំណូមពរនានា នៅខេត្តបាត់ដំបង<br>+ អញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់អំពីរបៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ឃុំ សង្កាត់ នៃខេត្តកំពង់ចាម របៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្តោតលើមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង របៀបដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដីស្រុកក្រុង របៀបដោះស្រាយទំនាស់ដែលថ្នាក់ ស្រុក ក្រុងបញ្ជូនមកថ្នាក់ខេត្ត និងការដោះស្រាយវិវាទផ្សេងៗ ការចូលរួមអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌក្នុងវង្វង់ដែនសមត្ថកិច្ចការអនុវត្តច្បាប់ ការងារផ្សព្វផ្សាយច្បាប់ និងការងារនីតិកម្ម ការអនុវត្តក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីរបស់សាលាដំបូង ព្រមទាំងសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ចំពោះការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌក្នុងកិច្ចការងារជាមួយសាលាដំបូងខេត្ត និងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។ | មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៨នាក់ ស្មើនឹង១២ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមក្នុងកម្មវិធីផ្សេងៗ នៅតាមបណ្តាភូមិភាគ និងឧបត្ថម្ភមន្ត្រីបំពេញការងារលើសម៉ោង និងថ្ងៃឈប់សម្រាកចំនួន០២លើក ។ |

៣.មុខងារតំណាង :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់សម្តេចប្រមុខរដ្ឋស្តីទី និងថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖<br>+ អញ្ជើញទទួលព្រះរាជដំណើររបស់ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម **សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ដែលបានយាងនិវត្តមកដល់មាតុប្រទេសវិញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ<br>+ អញ្ជើញជួបសំណេះសំណាល ជូនពរឆ្នាំថ្មី សាកសួរសុខទុក្ខអាជ្ញាធរ ក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈចលនាសាសនិកឥស្លាម មន្ត្រីរាជការ និវត្តជនជាមន្ត្រីនគរបាលចរាចរ ក្រុមគ្រូពេទ្យ និងនិស្សិតពេទ្យស្ម័គ្រចិត្ត ដែលបានចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តតាកែវ និងខេត្តកណ្តាល<br>+ អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធព្រះវិហារ កុដិសាលាអនុគណ សាលាពុទ្ធិកបឋមសិក្សា សមិទ្ធផលនានា និងពិធីស្រោចស្រពសុគន្ធវារីប្រគេនព្រះញាណវង្ស សៅរ៍ មុនី ព្រះរាជាគណៈថ្នាក់ត្រី នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល<br>+ អញ្ជើញជាអធិបតីក្នុងពិធីបង្សុកូល និងពិធីបុណ្យស្រោចស្រពសុគន្ធវារីបច្ច័យបួនគោរពជូនមាតា បិតា លោកឪពុកធំ | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីក្នុងពិធីផ្សេងៗ សរុបចំនួន៣៣៧លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវ ប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានឈ្វេងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងកម្មវិធីផ្សេងៗ នៅខេត្តព្រៃវែង ពោធិ៍សាត់ បាត់ដំបង កណ្តាល កំពត និងខេត្តកែប<br>- បានអមដំណើរសមាជិកព្រឹទ្ធសភា ចូលរួមកម្មវិធីសម្ពោធដាក់ឲ្យប្រើប្រាស់អណ្តូងទឹកស្អាតចំនួន ០២កន្លែង នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>- រៀបចំរបាំត្រុដិ និងរបាំជូនពរ ពិធីសូត្រមន្ត និងជប់លៀងអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ<br>- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់ និងរៀបចំអំណោយ ៣០កញ្ចប់ យកទៅជូនគណៈកម្មាធិការរៀបចំបុណ្យជាតិ អន្តរជាតិ សម្រាប់ចុះសួរសុខទុក្ខអ្នកជំងឺ និងកុមារកំព្រា<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៥០នាក់ ស្មើនឹង៧១ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភា |

**៣.មុខងារតំណាង** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់សម្តេចប្រមុខរដ្ឋស្តីទី និងថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖<br>+ អញ្ជើញទទួលព្រះរាជដំណើររបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដែលបានយាងនិវត្តន៍មកដល់មាតុប្រទេសវិញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ<br>+ អញ្ជើញជួបសំណេះសំណាល ជូនពរឆ្នាំថ្មី សាកសួរសុខទុក្ខអាជ្ញាធរ ក្រុមប្រឹក្សាឃុំ-សង្កាត់ គណៈចលនាសាសនិកឥស្លាម មន្ត្រីរាជការ និវត្តជនជាមន្ត្រីនគរបាលចរាចរ ក្រុមគ្រូពេទ្យ និងនិស្សិតពេទ្យស្ម័គ្រចិត្ត ដែលបានចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តតាកែវ និងខេត្តកណ្តាល<br>+ អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធព្រះវិហារ កុដិសាលាអនុគណ សាលាពុទ្ធិកបឋមសិក្សា សមិទ្ធផលនានា និងពិធីស្រោចស្រពសុគន្ធវារីប្រគេនព្រះញាណវង្ស សៅរ៍ មុនី ព្រះរាជាគណៈថ្នាក់ត្រី នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល<br>+ អញ្ជើញជាអធិបតីក្នុងពិធីបង្សុកូល និងពិធីបុណ្យស្រោចស្រពសុគន្ធវារីបច្ច័យបួនគោរពជូនមាតា បិតា លោកឪពុកធំ | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតីក្នុងពិធីផ្សេងៗ សរុបចំនួន៣៣៧លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានឈ្វេងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងកម្មវិធីផ្សេងៗ នៅខេត្តព្រៃវែង ពោធិ៍សាត់ បាត់ដំបង កណ្តាល កំពត និងខេត្តកែប<br>- បានអមដំណើរសមាជិកព្រឹទ្ធសភា ចូលរួមកម្មវិធីសម្ពោធដាក់ឲ្យប្រើប្រាស់អណ្តូងទឹកស្អាតចំនួន ០២កន្លែង នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>- រៀបចំរបាំត្រុដិ និងរបាំជូនពរ ពិធីសូត្រមន្ត និងជប់លៀងអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ<br>- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់ និងរៀបចំអំណោយ ៣០កញ្ចប់ យកទៅជូនគណៈកម្មាធិការរៀបចំបុណ្យជាតិ អន្តរជាតិ សម្រាប់ចុះសួរសុខទុក្ខអ្នកជំងឺ និងកុមារកំព្រា<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៥០នាក់ ស្មើនឹង៧១ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភា |

| | |
|---|---|
| ម្តាយធំ និងញាតិការទាំង៧សណ្ឋាន និង អបអរសាទរទេវតាឆ្នាំថ្មី នៅខេត្តកំពង់ចាម<br>+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខក្រុមគ្រួសារសព ឯកឧត្តម **ពិន តាំងសាន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ឧបាសិកា **ទា លីហួង** ដែលត្រូវជាម្តាយ លោកឧកញ៉ា **ឡាយ ប៊ុនប៉ា** និងសពលោក **សាយ សុផល** ជំនួយការផ្ទាល់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ព្រមទាំងចូលរួមបុណ្យគម្រប់ខួប១០០ថ្ងៃ ឧទ្ទិសកុសលជូន**សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរ៉ក្ស** អតីតអនុប្រធានទី១ ព្រឹទ្ធសភា នៅរាជធានីភ្នំពេញ<br>+ អញ្ជើញជាអធិបតី និងចូលរួមក្នុងពិធីសូត្រមន្ត និងជប់លៀង អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដើម្បីប្រោះព្រំសុំសេចក្តីសុខ និងសិរីសួស្តីវិបុលសុខគ្រប់ប្រការ ជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>+ អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និបាតកោះពេជ្រ<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងជំនួប | ចំនួន១២នាក់ ស្មើនឹង១២ច្បាប់<br>- ថតចម្លងឯកសារចំនួន០៤សំណើ អស់ក្រដាសចំនួន១,៤៣៤សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅតាមបណ្តាខេត្ត ក្រុងរាជធានីទាំង៨ភូមិភាគចំនួន៣៦៣នាក់ ស្មើនឹង១០៥លើក<br>- ទទួលលិខិតចូលចំនួន១,៤៥១ច្បាប់ និងបញ្ជូនលិខិតចេញចំនួន០៥ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗសរុបចំនួន៧៩លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងពិធីផ្សេងៗចំនួន៦៧នាក់ ស្មើនឹង០៤លើក<br>- ផ្តល់រូបថតចំនួន៤៧០សន្លឹក និងអត្ថបទសារព័ត៌មានចំនួន២៨អត្ថបទ ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំប័ណ្ណជូនពរ និងសារជូនពរចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរឆ្នាំ២០១៧ ចំនួន៦,១៥០សន្លឹក<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១៤៥នាក់ ធ្វើប័ណ្ណសមាជិកចំនួន០៥នាក់ ខ្ចីសៀវភៅចំនួន៥១ក្បាល និងសងវិញចំនួន៥០ក្បាល<br>- ទទួលឯកសារសៀវភៅពីអង្គការ ស្ថានទូត ក្រសួង |

| | |
|---|---|
| សម្តែងការគួរសម និងពិភាក្សាការងារ រវាងក្រុមមិត្តភាពកម្ពុជា-ចិន ជាមួយវិនិយោគិន នៅសមាគមក្រុមមិត្តភាពកម្ពុជា-ចិន<br>+ អញ្ជើញនាំយកទេយ្យទាន ដើម្បីរៀបចំបង្សុកូលឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធលោកជំទាវ ភូ ធឿន និងបុព្វការីជនដែលបានពលីជីវិតក្នុងការរំដោះជាតិ និងការកសាងប្រទេសជាតិ នៅវត្តប្រាំបីមុំ ខេត្តតាកែវ<br>- បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន០១ករណី ទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០៩ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី និងបានឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៣នាក់<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីទូទាំងប្រទេសចំនួន២០៨លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការ | ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រឹត្តិបត្រទស្សនាវដ្តីចំនួន២១០ក្បាល កាសែតចំនួន១៩៨ច្បាប់ និងព្រះរាជក្រមចំនួន៧០ច្បាប់<br>- ថត និងផ្សព្វផ្សាយព័ត៌មានផ្សេងៗចំនួន៧៨លើក។ |

| | |
|---|---|
| អនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និង គោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៧លើក ។ | |

## ៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :

| វចនាសម្ព័ន្ធនយោបាយ | វចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចប្រមុខរដ្ឋស្តីទីបានទទួលសារតាំងពីឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋក្រូអាស៊ី<br>- សម្តេចប្រមុខរដ្ឋស្តីទី និងថ្នាក់ដឹកនាំព្រឹទ្ធសភាបានអនុញ្ញាតឲ្យនាយករដ្ឋមន្ត្រី និងសមាជិកមជ្ឈឹមបក្សកុម្មុយនីស្តវៀតណាម មេបញ្ជាការយោធភូមិភាគ៧ និងគណៈប្រតិភូបញ្ជាការយោធភូមិភាគ៧ ក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងអនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សភាប្រជាជនទូទាំងប្រទេស នៃសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរសម និងសវនាការ<br>- សម្តេចប្រធានព្រឹទ្ធសភា បានជួបសំណេះសំណាល និងពិភាក្សាការងារជាមួយអគ្គរាជទូតខ្មែរថ្មី ប្រចាំប្រទេសថៃ ឡាវ ឥណ្ឌូនេស៊ី អាល្លឺម៉ង់ អង់គ្លេស កូរ៉េខាងជើង និងសិង្ហបុរី<br>- សមាជិក សមាជិកាព្រឹទ្ធសភាបាន៖ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- ធ្វើពិព័រណ៌រូបភាព បដា ពាក្យស្លោក និងធ្វើហ្វុងអក្សរក្នុងពិធីផ្សេងៗចំនួន០៥លើក<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវ សិក្ខាសាលា គណៈប្រតិភូជាតិ អន្តរជាតិមកបំពេញទស្សនកិច្ចក្នុង និងក្រៅប្រទេសចំនួន៣២លើក<br>- រៀបចំសម្អាត តុបតែងសាល បម្រើ និងផ្តល់សេវាផ្គត់ផ្គង់សម្ភារៈ ភេសជ្ជៈ ក្នុងពិធីផ្សេងៗចំនួន១០លើក ស្មើនឹង៨២នាក់<br>- ថតចម្លងឯកសារចំនួន០៦សំណើ អស់ក្រដាសចំនួន១៣,០៧៣សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរាជធានីភ្នំពេញ និង |

| | |
|---|---|
| + ជួបពិភាក្សាការងារជាមួយអនុប្រធានវិទ្យាស្ថានគូបា ដើម្បីមិត្តភាពជាមួយប្រជាជាតិនៅលើពិភពលោក (ICAP)<br>+ អនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតឡាវប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អគ្គកុងស៊ុលឡាវនៅខេត្តស្ទឹងត្រែង និងសហការី ព្រមទាំងទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំជនជាតិកូរ៉េ ចូលជួបសំណេះសំណាលសម្តែងការគួរសម និងសវនាការ<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភា ( IPU ) លើកទី១៣៦ នៅប្រទេសបង់ក្លាដេស ប្រជុំអន្តរជាតិស្តីពី ការដោះស្រាយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន តួនាទីរបស់រដ្ឋាភិបាល សង្គមស៊ីវិល និងអង្គការអន្តរសាសនា នៅសាធារណរដ្ឋឥណ្ឌា និងប្រជុំគណៈកម្មការកិច្ចការសភា នៃសភាប្រើប្រាស់ភាសាបារាំង (APF) នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។ | ទៅតាមបណ្តាខេត្ត ក្រុង រាជធានីទាំង៨ភូមិភាគ ចំនួន៥០នាក់ ស្មើនឹង៣៣លើក និងទៅប្រទេសវៀតណាមចំនួន២១នាក់ ស្មើនឹង០៣លើក<br>- ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត ធ្វើសំណើ និងលិខិតឆ្លើយតបទៅក្រសួងផ្សេងៗ និងបណ្តាអង្គទូតនានាចំនួន១៣លើក<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១២នាក់ ស្មើនឹង០៤ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងឧបត្ថម្ភមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ថ្លៃចំណាយផ្សេងៗចំនួន១៤លើក<br>- រៀបចំបែបបទ និងនីតិវិធីសម្រាប់ដំណើរបេសកកម្មជូនសមាជិកព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន០៣លើក<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ ដោយប្រើប្រាស់កម្លាំងសរុបចំនួន៦៧នាក់ ស្មើនឹង០២លើក<br>- អគ្គលេខាធិការព្រឹទ្ធសភាអញ្ជើញចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៣៦ នៅប្រទេសបង់ក្លាដេស<br>- ទំនាក់ទំនងជាមួយស្ថានទូតបារាំង ទីភ្នាក់ងារសាកលវិទ្យាល័យប្រើប្រាស់ភាសាបារាំង ក្រសួងស្ថាប័ន និងបណ្ណាល័យនានា សម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា និងបំពេញបេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ |

| | |
|---|---|
| | វគ្គបណ្តុះបណ្តាល និងការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - រៀបចំបែបបទសុំជំនួយពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសាងសង់សាលប្រជុំពេញអង្គថ្មី<br>- បានធ្វើបែបបទស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលថ្មី ព្រឹទ្ធសភា<br>- កិច្ចសហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន។ | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៤៦ច្បាប់<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន២៩ច្បាប់<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០១៦<br>- ប្រជុំអន្តរគណៈកម្មការ ដើម្បីពិនិត្យ និងកែសម្រួលសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការសិក្សារៀបចំសេចក្តីសម្រេចស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការរៀបចំធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌថ្មី<br>**+ការងារបណ្តុះបណ្តាលធនធានមនុស្ស :**<br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុង និង |

| | |
|---|---|
| | ក្រៅប្រទេស សរុបចំនួន០៣វគ្គ មានសិក្ខាកាមចូលរួមចំនួន៣៧នាក់<br>- បានសហការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) បើកវគ្គភាសាអង់គ្លេសសម្រាប់មន្ត្រីសភា និងអនុវត្តកម្មវិធីកម្មសិក្សាពីនិស្សិតក្នុងប្រទេស និងក្រៅប្រទេស<br>**+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :**<br>- ប្រជុំសិក្សាអំពីអង្គភាពថវិកាតាមកម្មវិធី និងសមិទ្ធកម្មកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ<br>- រៀបចំកសាងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (២០១៨-២០២០) និងគម្រោងថវិកាប្រចាំឆ្នាំ២០១៨ របស់ព្រឹទ្ធសភា<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែមេសាឆ្នាំ២០១៧ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិច ជួសជុលរថយន្ត និងសម្ភារៈឧបករណ៍បច្ចេកទេសផ្សេងៗ ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធ កែលម្អសោភ័ណ្ឌភាពក្នុងបរិវេណព្រឹទ្ធសភាចំនួន ៨៧លើក<br>- ទូទាត់លទ្ធកម្មឯកសណ្ឋានមន្ត្រីរាជការឆ្នាំ២០១៧ បោះពុម្ពព្រឹត្តិបត្រភាសាខ្មែរ សម្ភារៈការិយាល័យ អនាម័យ ត្រីមាសទី១ ឆ្នាំ២០១៧ |

| | |
|---|---|
| | - បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ និងសិក្ខាសាលាចំនួន២៩សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ អាហារសម្រន់ និងភេសជ្ជៈចំនួន៣៣សំណើ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល ផ្តល់សេវាបម្រើភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន ០៧លើក មានអ្នកចូលរួមចំនួន២០២នាក់<br>- ផ្តល់សេវាថវិកាសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងទូទាត់ថ្លៃចំណាយផ្សេងៗ ចំនួន១១៣លើក<br>- ថតចម្លងឯកសារ និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន៤៤សំណើ អស់ក្រដាសចំនួន ១៤,៣៩៧សន្លឹក ព្រមទាំងផ្តល់សេវាដឹកជញ្ជូនទៅតាមបណ្តាខេត្ត ក្រុងទាំង៨ភូមិភាគ និងក្នុងរាជធានីភ្នំពេញចំនួន៩៨៣នាក់ ស្មើនឹង៨៣លើក<br>**+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់:**<br>- សិក្សាប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី ជួសជុលអគារមូលនិធិអភិវឌ្ឍន៍<br>- ជួសជុលនៅស្នាបខាងស្តាំអគារក្រហម និងសង់បន្ទប់ទឹកបន្ថែមសម្រាប់សាលសិក្ខាសាលាខាងត្បូង<br>- រៀបចំសុំគោលការណ៍ ដើម្បីត្រៀមរៀបចំជួសជុលអគារសាលប្រជុំពេញអង្គចាស់<br>- រៀបចំកែលម្អសាលប្រជុំ បន្ទប់ទទួលភ្ញៀវ បន្ទប់ទឹក |

| | |
|---|---|
| | និងរៀបចំបណ្តាញអគ្គិសនីនៅលើអគារក្រហម<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភាឲ្យមានសោភ័ណ្ឌភាពល្អ<br>- គាស់ការ៉ូឡា រៀបចំថ្មម៉ាបថ្មី ចាក់សាបស៊ីម៉ង់ត៍ និងគូសគំនូសចរាចរណ៍ឡើងវិញ<br>- ប្តូរពិដាន បិទផ្លាស្ទិចស្រអាប់ ខាត់ លាប ទ្វារកញ្ចក់ បង្អួច ដៃទ្វារនៅលើអគារក្រហមស្លាបខាងលិច នាយកដ្ឋានព័ត៌មាន នាយកដ្ឋានរដ្ឋបាល និងអគារ B<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច ប្តូរសោគុ ដៃទ្វារ និងដេរក្រណាត់គ្របកៅអីសរុបចំនួន៦០៤គ្រឿង និងបណ្តាញទឹកចំនួន០៩ខ្សែ<br>- បិទលេខកូដសម្ភារៈសារពើភ័ណ្ឌចំនួន២៣គ្រឿង<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន៤៥គ្រឿង។ បានUpload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាសរុបចំនួន១៤៧ចំណងជើង<br>+ការងារផ្សេងៗ:<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន១៩លើក<br>- បានរៀបចំ និងបញ្ចូលលេខកូដឯកសារសៀវភៅច្បាប់ សៀវភៅជំនាញផ្សេងៗ និងចុះបញ្ជីឯកសារ |

| | |
|---|---|
| | បោះត្រា បិទប័ណ្ណខ្ទី និងសង់សៀវភៅ ជួសជុល និងផ្លាស់ប្តូរលេខកូដចាស់ៗសរុបចំនួន៩៨ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និង បញ្ចូលសៀវភៅតាម PMB E-Library បណ្តាញ Facebook សរុបចំនួន៤,៦២៦ក្បាល ។ |

II.ទិសដៅការងារខែឧសភា ឆ្នាំ២០១៧

**១.មុខងារនីតិកម្ម:**

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្តសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី១០

-ត្រៀមបន្តនីតិវិធីពាក់ព័ន្ធច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែង និងពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌សមាជិកព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាថ្មី ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា :**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ក្រុង ។

**៣.មុខងារតំណាង :**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត ក្រុង (កម្មវិធីសម្ពោធសមិទ្ធផលវត្តចំនួន០១)

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា ។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ក្នុងនាមជាប្រធានព្រឹទ្ធសភា ជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា ព្រមទាំងពិធីទទួលសារតាំងទូតថ្មី ( ទូត Croatia, Finland និង Rwanda)

+ត្រៀមការចុះហត្ថលេខារវាងលេខាធិការដ្ឋាន(APF) និងវិទ្យាស្ថានសភាកម្ពុជា (PIC) និងកម្មវិធីបណ្តុះបណ្តាលពីចំណាយរបស់លេខាធិកាដ្ឋាន(APF) ព្រមទាំងសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា (PIC) និង(IPU)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស (ព្យួររហូតដល់ក្រោយថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧)

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា៖ ASGPF, SES, CIM, KAS, GIZ, MAX PLANCK FOUNDATION, UNESCO, JICA និង KOICA

-តាមដានគម្រោងសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

-បន្តបណ្តុះបណ្តាល PBO អ្នកស្រាវជ្រាវទូទៅ និងអ្នកស្រាវជ្រាវខាងទំនាក់ទំនងអន្តរជាតិ និងទំនាក់ទំនងលេខាធិការដ្ឋាន APF អំពីសហប្រតិបត្តិការបច្ចេកទេស បន្ទាប់ពីផលិតឯកសារ ៤ Modules

-សហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាលខាងការស្រាវជ្រាវ និងការអនុវត្ត MOU សហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវសភា ឥណ្ឌា និងប៉ាគីស្ថាន ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-បន្តរៀបចំជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារៈប្រើប្រាស់៖ ការជួសជុលផ្នែកស្លាបស្តាំអគារក្រហម សង់បន្ទប់ទឹកបន្ថែមសម្រាប់សាលសិក្ខាសាលាខាងត្បូង រៀបចំជូរកម្រាលព្រំនៅអគារក្រហមមាន បន្ទប់ទទួលភ្ញៀវ បន្ទប់រង់ចាំ បន្ទប់គណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្ទប់ឆ្លងកាត់កណ្តាល ព្រមទាំងរៀបចំគូសគំនូសចំណតរថយន្ត និងសញ្ញាបង្ហាញផ្លូវ

-សិក្សាប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-បន្តប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំអន្តរគណៈកម្មការវិសោធនកម្មច្បាប់លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងលក្ខន្តិកៈសមាគមសង្គហៈមន្ត្រីរាជការក្រុមនីតិប្បញ្ញត្តិ

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំគណៈកម្មការរៀបចំធ្វើសមាហរណកម្មមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលក្នុងក្របខ័ណ្ឌថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលជាជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រកពពីកូរ៉េ ជប៉ុន ចិន អូស្រ្តាលី នូវែលហ្សេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី ថៃ និងប្រទេសផ្សេងៗទៀត

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តថវិកាតាមកម្មវិធីដាក់ស្តែងក្នុងត្រីមាសទី២ ឆ្នាំ២០១៧

-រៀបចំថវិកាឆ្នាំ២០១៨ និងយុទ្ធសាស្រ្តថវិកា៣ឆ្នាំរំកិល

-រៀបចំផែនការប្រតិបត្តិឆ្នាំ២០១៧ បច្ចុប្បន្នភាពផែនការយុទ្ធសាស្រ្ត១០ឆ្នាំ រៀបចំគម្រោងថវិកាសម្រាប់ឆ្នាំ២០១៨។

## III.សេចក្តីសន្និដ្ឋាន

ក្នុងខែមេសានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំពិធីសូត្រមន្ត និងជប់លៀងអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ និងពិធីផ្សេងៗទៀត ជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបានដោយរលូន ។ ជាមួយគ្នានេះ បានបំពេញការងារយ៉ាងសកម្មដោយបានរៀបចំប្រជុំគណៈកម្មាធិការអចិន្រ្តៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក ។ ចំពោះមុខងារតាមដានការអនុវត្តច្បាប់ បានចុះសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មាន នៅខេត្តបាត់ដំបង និងខេត្តផ្សេងៗទៀត។ ដោយឡែកលើមុខងារតំណាង បានជួបសំណេះសំណាលជាមួយចលនាសាសនិកឥស្លាមកម្ពុជា និវត្តជន និងប្រជាពលរដ្ឋ ព្រមទាំងរៀបចំពិធីស្រោចស្រពសុគន្ធវារី បច្ច័យបួន រួមទាំងចូលរួមរំលែកទុក្ខក្រុមគ្រួសារសព រួមទាំងពិធីផ្សេងៗទៀត នៅរាជធានីភ្នំពេញ ខេត្តកណ្តាល តាកែវ កោះកុង ពោធិ៍សាត់ ព្រៃវែង ស្វាយរៀង កំពង់ចាម និងខេត្តបាត់ដំបង ។ មុខងារអភិវឌ្ឍស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួន ។ លើការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ត្រូវបានពង្រឹងពង្រីក និងលើកកម្ពស់តាមរយៈការចូលរួមប្រជុំមហាសន្និបាត

សហភាពអន្តរសភា IPU លើកទី១៣៦ នៅប្រទេសបង់ក្លាដេស និងសហប្រតិបត្តិការជាមួយដៃគូនានា ដែលបានប្រព្រឹត្តទៅដោយរលូន និងមានលទ្ធផលជាផ្លែផ្កា។

ភ្នំពេញ, ថ្ងៃទី ខែឧសភា ឆ្នាំ២០១៧

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ